## ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ១១៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួល មាត្រា២៧ និងមាត្រា៣៤ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួល អគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូ... 

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គ-នាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧៩ អនក្រ.បក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មចំណុះអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនា-សម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

### មាត្រាមួយ .-

មាត្រា២៧ និងមាត្រា៣៤ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មទៅជាអគ្គ-នាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

### មាត្រា២៧.- ថ្មី

អគ្គនាយកដ្ឋានកសិកម្ម មាននាយកដ្ឋានចំណុះចំនួន៩ និងមន្ទីរពិសោធន៍ជាតិកសិកម្មចំនួន១ មានថ្នាក់ស្មើនឹងនាយកដ្ឋានដូចខាងក្រោម៖

១- នាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ

២- នាយកដ្ឋានដំណាំស្រូវ

៣- នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ

៤- នាយកដ្ឋានដំណាំឧស្សាហកម្ម

៥- នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ

៦- នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម

៧- នាយកដ្ឋានវិស្វកម្មកសិកម្ម

៨- នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

៩- នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម

១០- មន្ទីរពិសោធន៍ជាតិកសិកម្ម។

អង្គការលេខរបស់អគ្គនាយកដ្ឋានកសិកម្មត្រូវបានកំណត់ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៣៤ .– ថ្មី**

នាយកដ្ឋានវិស្វកម្មកសិកម្មមានភារកិច្ចដូចខាងក្រោម៖

- ស្រាវជ្រាវ និងកំណត់បែងចែកតំបន់ប្រើប្រាស់គ្រឿងយន្តកសិកម្ម ឧបករណ៍កសិកម្ម ម៉ាស៊ីនកសិកម្មតាមប្រភេទដី និងតាមមុខដំណាំ ដើម្បីអភិវឌ្ឍវិស័យកសិកម្ម
- រៀបចំគោលការណ៍ លិខិតបទដ្ឋានអំពីសក្តានុពល និងអំពីប្រសិទ្ធភាពគ្រឿងយន្តកសិកម្ម ក្នុងផលិតកម្មដាំដុះ
- ស្រាវជ្រាវ និងផ្តួចផ្តើមគំនិតផលិតនិងកែច្នៃឧបករណ៍កសិកម្ម និងមានវិធានការនិងមធ្យោបាយស្រាវជ្រាវ ដើម្បីបន្ថយការប្រើប្រាស់កម្លាំងមនុស្សក្នុងការងារផលិតកម្មកសិកម្ម
- ណែនាំ និងផ្សព្វផ្សាយបច្ចេកទេសដល់អ្នកប្រើប្រាស់គ្រឿងយន្តកសិកម្ម ក្នុងផលិតកម្មកសិកម្ម ក្នុងនិងក្រោយពេលប្រមូលផលដើម្បីបង្កើន កែលម្អផលិតកម្ម និងផលិតភាពកសិកម្ម
- ទំនាក់ទំនង និងសម្របសម្រួលជំរុញការងារវិនិយោគរបស់វិស័យឯកជន ដើម្បីចូលរួមវិនិយោគសម្ភារ ឧបករណ៍គ្រឿងយន្តកសិកម្ម ដែលមានលក្ខណៈកាន់តែសមស្របទៅនឹងលក្ខខណ្ឌនៃប្រទេសកម្ពុជា
- សេនាធិការបច្ចេកទេស និងផ្តល់សេវាលើការវាយតម្លៃប្រសិទ្ធភាពនៃការប្រើប្រាស់គ្រឿងយន្តកសិកម្ម
- សិក្សា និងកំណត់សក្តានុពលធនធានទឹកសម្រាប់ស្រោចស្រពក្នុងករណីចាំបាច់
- សិក្សាពីលទ្ធភាពនិងបំពាក់បច្ចេកវិទ្យាទំនើបក្នុងការផ្គត់ផ្គង់ទឹកសម្រាប់បម្រើដល់ការដាំដុះដំណាំរួមផ្សំ សាកវប្បកម្ម ដំណាំបន្លែ ការចិញ្ចឹមសត្វ និងវារីវប្បកម្ម នៅតាមសហគមន៍កសិកម្ម ដែលត្រូវបានបង្កើតឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីទាញយកទឹកតាមរយៈការសាងសង់ប្រឡាយជើងក្អែប ការជីកអណ្តូង ការបូម និងតាមមធ្យោបាយផ្សេងៗទៀត បម្រើឲ្យសហគមន៍កសិកម្ម ក្នុងការដាំដុះប្រពលវប្បកម្មដំណាំ ពិពិធភាវូបនីយកម្ម និងការលើកកម្ពស់ផលិតភាពកសិកម្ម
- ចូលរួមធ្វើអន្តរាគមន៍ក្នុងការដោះស្រាយបញ្ហាទឹកជូនដល់កសិករ ក្នុងពេលកសិករជួបប្រទះនឹងបញ្ហាប្រឈមទៅនឹងគ្រោះធម្មជាតិដូចជារាំងស្ងួត និងទឹកជំនន់ ដែលបណ្តាលមកពីបម្រែបម្រួលអាកាសធាតុ
- អនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានប្រគល់ជូន។

នាយកដ្ឋានវិស្វកម្មកសិកម្ម ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូបនិងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រាពីរ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធភ្ជាប់អនុក្រឹត្យ លេខ.១១៨......អនក្រ.បក ចុះថ្ងៃទី.២៦...ខែ.កក្កដា....ឆ្នាំ២០១៧
"ស្តីពីការកែសម្រួល មាត្រា២៧ និងមាត្រា៣៤ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួល អគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកស្សិត្រសាស្ត្រ និងកែលម្អដីកសិកម្ម ទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ"

## អង្គការលេខរបស់អគ្គនាយកដ្ឋានកសិកម្ម

**អគ្គនាយកដ្ឋានកសិកម្ម**

- នាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ
- នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម
- នាយកដ្ឋានដំណាំស្រូវ
- នាយកដ្ឋានវិស្វកម្មកសិកម្ម
- នាយកដ្ឋានសាកវប្បកម្មនិងដំណាំរួមផ្សំ
- នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
- នាយកដ្ឋានដំណាំឧស្សាហកម្ម
- នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម
- នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ
- មន្ទីរពិសោធន៍ជាតិកសិកម្ម